**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខៈ ០៩៣/ន.ព
២០១៦

# សេចក្តីប្រកាសព័ត៌មាន

បន្ទាប់ពីបានសំរេចភារកិច្ចអន្តរជាតិក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិអាណត្តិមួយឆ្នាំនៅសាធារណរដ្ឋស៊ូដង់ខាងត្បូង សាធារណរដ្ឋម៉ាលី និងអាហ្វ្រិកកណ្តាល កងកម្លាំងអាវុធហត្ថលេខ ១៦៨ ចំនួន៧៣នាក់ កងកំទេចគ្រាប់មិនទាន់ផ្ទុះលេខ ៣១២ ចំនួន១៦៨នាក់ និងកងវិស្វកម្មព្រលានយន្តហោះលេខ ៩១៨ ចំនួន១៨៤នាក់ បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងជោគជ័យមកកាន់មាតុភូមិវិញ។

ពិធីទទួលដំណើរមាតុភូមិនិវត្តន៍របស់កងយោធពលខេមរភូមិន្ទពីបំពេញបេសកកម្មអន្តរជាតិក្រោមឆ័ត្រអ.ស.ប ទាំង៣កងនេះ ត្រូវបានរៀបចំធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងមានការអញ្ជើញចូលរួម ពីតំណាងអ.ស.ប ប្រចាំនៅកម្ពុជា ភ្ញៀវកិត្តិយស៍ជាតិ និងអន្តរជាតិ នៅវេលាម៉ោង៨ព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ នៅមូល ដ្ឋានទ័ពអាកាសពោធិចិនតុង។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦